**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខៈ ៧៤៥១ សសរ

# សេចក្ដីសម្រេច
# ស្ដីពី
# ការដាក់ឱ្យអនុវត្តសៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ ប.ក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៥៨ អនក្រ ប.ក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្ដីពីកាបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ ប.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីអត្រានុកូលដ្ឋាន របស់ក្រសួងមហាផ្ទៃ
- បានឃើញសេចក្ដីណែនាំលេខ០០៨ សណន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ស្ដីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយយុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត របស់ក្រសួងមហាផ្ទៃ
- បានឃើញសេចក្ដីណែនាំលេខ០២៩ សណន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ ស្ដីពីវិធានការពង្រឹងការអនុវត្តការងារស្ថិតិអត្រានុកូលដ្ឋាន របស់ក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរចាំបាច់នៃការងារ

# សម្រេច

**ប្រការ១._**

ត្រូវបានដាក់ឱ្យអនុវត្តសៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលប្រើប្រាស់ដោយមេភូមិ ដើម្បីតាមដានព្រឹត្តិការណ៍កំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលបានកើតឡើងនៅតាមភូមិនីមួយៗ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២._**

សៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ជាឧបករណ៍សម្រាប់កត់ត្រានូវរាល់ព្រឹត្តិការណ៍ខាងលើ ដែលអាចជួយដល់មេភូមិឱ្យមានមូលដ្ឋានទិន្នន័យច្បាស់លាស់ ដើម្បីមានលទ្ធភាពជំរុញការចុះបញ្ជីកំណើត(ក្នុង៣០ថ្ងៃ) មរណភាព(ក្នុង១៥ថ្ងៃ) ឱ្យបានទាន់ពេលវេលា និងទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍រវាងបុរស និងនារីមានអាយុក្រោមច្បាប់កំណត់។

ការដាក់ឱ្យប្រើប្រាស់សៀវភៅនេះ នឹងផ្តល់ភាពងាយស្រួលដល់ថ្នាក់រដ្ឋបាលនីមួយៗ ក្នុងការប្រមូលចងក្រងទិន្នន័យស្ថិតិអត្រានុកូលដ្ឋាន និងលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងគោលដៅឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា លើការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នៅថ្នាក់តំបន់អាស៊ី និងប៉ាស៊ីហ្វិក។

**ប្រការ៣._**

រដ្ឋបាលរាជធានី ខេត្ត ដោយមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន នៃទីចាត់ការរដ្ឋបាលសាលារាជធានី ខេត្ត ជាជំនួយការ ត្រូវបំពេញតួនាទីភារកិច្ចបន្ថែមលើតួនាទីភារកិច្ចបច្ចុប្បន្ន ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកា ដើម្បីពង្រឹងការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងរៀបចំវគ្គបណ្តុះបណ្តាល ដល់អភិបាល ឬអភិបាលរងទទួលបន្ទុក ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ និងមន្ត្រីពាក់ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ អំពីរបៀបកត់ត្រាសៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។
- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ យ៉ាងតិចមួយត្រីមាសម្តង ដើម្បីធ្វើការផ្ទៀងផ្ទាត់អំពីចំនួនស្ថិតិដែលបានចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងឃុំ សង្កាត់ ជាមួយនឹងចំនួនស្ថិតិដែលបានកត់ត្រាក្នុងសៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។
- រៀបចំប្រជុំប្រចាំត្រីមាសជាមួយថ្នាក់ក្រុង ស្រុក ខណ្ឌ និងតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) និងអាចអញ្ជើញតំណាងឃុំ សង្កាត់ ចូលរួមតាមការចាំបាច់ ដើម្បីពិនិត្យពីវឌ្ឍនភាពនៃការអនុវត្តការងារអត្រានុកូលដ្ឋាន ។

- ផ្តល់របាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តការងារអត្រានុកូលដ្ឋានដល់ គ.ក.ស.ក រាជធានី ខេត្ត តាមការស្នើសុំ។
- ផ្តល់របាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទ មកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ តាមពេលវេលាកំណត់។

**ប្រការ៤._**

រដ្ឋបាលក្រុង ស្រុក ខណ្ឌដោយមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ជាជំនួយការ ត្រូវបំពេញតួនាទីភារកិច្ចបន្ថែមលើតួនាទីភារកិច្ចបច្ចុប្បន្ន ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកា ដើម្បីពង្រឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងសហការជាមួយថ្នាក់រាជធានី ខេត្ត ក្នុងការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងមន្ត្រីពាក់ព័ន្ធអំពីរបៀបកត់ត្រាសៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។
- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់ឃុំ សង្កាត់ យ៉ាងតិចពីរខែម្តង ដើម្បីធ្វើការផ្ទៀងផ្ទាត់អំពីចំនួនស្ថិតិដែលបានចុះបញ្ជីអត្រានុកូលដ្ឋានក្នុងឃុំ សង្កាត់ ជាមួយនឹងចំនួនស្ថិតិដែលបានកត់ត្រាក្នុងសៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។
- រៀបចំប្រជុំប្រចាំត្រីមាសជាមួយថ្នាក់ឃុំ សង្កាត់ ដើម្បីពិនិត្យពីវឌ្ឍនភាពនៃការអនុវត្តការងារអត្រានុ-កូលដ្ឋាន ដោយមានការចូលរួមពីតំណាង គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ និងតំណាងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) ឃុំ សង្កាត់។
- ផ្តល់របាយការណ៍ពាក់ព័ន្ធការអនុវត្តការងារអត្រានុកូលដ្ឋានដល់ គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ និងចូលរួមកិច្ចប្រជុំតាមការអញ្ជើញ។
- ផ្តល់របាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទ មករាជធានី ខេត្ត តាមពេលវេលាកំណត់។

**ប្រការ៥._**

ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានមេឃុំ ចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋាន និងមានស្មៀនឃុំ សង្កាត់ ជាជំនួយការ ត្រូវបំពេញតួនាទីភារកិច្ចបន្ថែមលើតួនាទីភារកិច្ចបច្ចុប្បន្ន ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកា ដើម្បីពង្រឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងសហការជាមួយថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងការបណ្តុះបណ្តាលដល់មេភូមិ អនុភូមិ សមាជិកភូមិ អំពីរបៀបកត់ត្រាសៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។
- ត្រូវតាមដាន ត្រួតពិនិត្យ និងគាំទ្រ ដល់មេភូមិ ឬអនុភូមិ ឬសមាជិកភូមិ ដែលកំពុងប្រើប្រាស់សៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព យ៉ាងតិចមួយខែម្តង ដើម្បីធ្វើការផ្ទៀងផ្ទាត់អំពីចំនួនស្ថិតិដែលបានចុះបញ្ជីអត្រានុកូលដ្ឋានក្នុងឃុំ សង្កាត់ ជាមួយនឹងចំនួនស្ថិតិដែលបានកត់ត្រាក្នុងសៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។

- របាយការណ៍អំពីការអនុវត្តការងារអត្រានុកូលដ្ឋានរៀងរាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងតាមការចាំបាច់។
- ផ្តល់របាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទ មកក្រុង ស្រុក ខណ្ឌ តាមពេលវេលាកំណត់។

**ប្រការ៦._**

មេភូមិ អនុភូមិ និងសមាជិកភូមិ ត្រូវជួយក្រុមប្រឹក្សាឃុំ សង្កាត់ បំពេញភារកិច្ច ដូចខាងក្រោម៖

- កត់ត្រាជាប្រចាំនូវព្រឹត្តិការណ៍ពាក់ព័ន្ធនឹងកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលបានកើតឡើងនៅក្នុងភូមិរបស់ខ្លួន ចូលទៅក្នុងសៀវភៅស្រង់ស្ថិតិខាងលើ
- របាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់អំពីស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលបានកើតឡើងនៅក្នុងភូមិរបស់ខ្លួន ជាពិសេសនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវផ្ទៀងផ្ទាត់ចំនួនស្ថិតិដែលបានកត់ត្រានៅក្នុងសៀវភៅស្រង់ស្ថិតិរបស់ខ្លួន ជាមួយនឹងស្ថិតិដែលបានចុះបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋានឃុំ សង្កាត់
- ចូលរួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីសារប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ
- ណែនាំដល់ឪពុក ម្តាយទារក សាច់ញាតិរបស់អ្នកស្លាប់ សាមីខ្លួនដែលបានរៀបអាពាហ៍ពិពាហ៍ ឬរួមរស់ក្នុងស្ថានភាពជាប្តីប្រពន្ធ ឱ្យទៅចុះបញ្ជីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីតម្លៃសេវារដ្ឋបាលលើការងារអត្រានុកូលដ្ឋានដល់ប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន។

**ប្រការ៧._**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នីមួយៗត្រូវមានថវិកាសម្រាប់ធ្វើការបណ្តុះបណ្តាល និងគាំទ្រដល់ដំណើរការប្រើប្រាស់សៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលប្រើប្រាស់ដោយមេភូមិ។

**ប្រការ៨._**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវប្រើប្រាស់ទម្រង់របាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានកំណើត អាពាហ៍ពិពាហ៍ និងមរណភាព (ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ) ជំនួសឱ្យទម្រង់របាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ នៃសេចក្តីណែនាំលេខ០២៩ សណន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីវិធានការពង្រឹងការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាន។ ដោយឡែកទម្រង់របាយការណ៍ ស្តីពីការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងឆ្នាំដែលកន្លងផុត និងក្នុងឆ្នាំដែលកំពុងអនុវត្ត របាយការណ៍ស្តីពីចំណូលដែលបានមកពីការជាវក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ របាយការណ៍ស្តីពីស្ថិតិប្រជាពលរដ្ឋប្រចាំឆមាស/ឆ្នាំ និង

របាយការណ៍ស្ដីពីការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ នៃសេចក្ដីណែនាំលេខ០២៩ សណន ខាងលើត្រូវអនុវត្តបន្ត។

**ប្រការ៩._**

សេចក្ដីសម្រេចនេះត្រូវបានដាក់ឱ្យអនុវត្តជំនួសផែនការណែនាំលេខ ០១៦ ផ.ក.ណ.ន ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ ស្ដីពីការជំរុញការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យបានប្រសើរឡើងក្នុងស្រុកគោលដៅចំនួន០៣ នៃខេត្តព្រៃវែង ស្វាយរៀង និងខេត្តកំពង់ស្ពឺ និងសេចក្ដីជូនដំណឹងលេខ១៧៧៧ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការជំរុញការចុះបញ្ជីអត្រានុកូលដ្ឋានឱ្យបានល្អប្រសើរនៅក្នុងស្រុក ខណ្ឌ និងឃុំ សង្កាត់គោលដៅ ដែលគាំទ្រដោយអង្គការយូនីសេហ្វ។

**ប្រការ១០._**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល:</u>**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- លេខាធិការ គ.ជ.អ.ប
- ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ

  ដើម្បីជូនជ្រាប
- ដូចប្រការ១០

  ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ